**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ...៥៧១២...សហវ....អថ

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩

**ជម្រាបជូន**
**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**កម្មវត្ថុ** : ករណីសំណើសុំអនុម័តការចរចាថ្លៃ និងប្រគល់កិច្ចសន្យាស្តីពីការងារស្ថាបនាផ្លូវខេត្តដោយចាក់ដីសពង្រីក និងលើកកម្ពស់តួថ្នល់សងខាង រួចក្រាលក្រួសក្រហម ប្រវែង ៣ ៧០០ម ទទឹង ៨ម ស្ថាបនាលូបេតុងមុខកាត់ ១ម សរុបចំនួន ០៣កន្លែង (១ជួរ ចំនួន ០២កន្លែង និង២ជួរ ចំនួន ០១កន្លែង) ដាំបង្គោលនាំផ្លូវ ចំនួន ១២ដើម និងដាក់ស្លាកព័ត៌មានគម្រោង ចំនួន ០២ស្លាក ស្ថិតលើកំណាត់ផ្លូវខេត្តលេខ៧១C បំបែកពីផ្លូវជាតិលេខ៧ ត្រង់គ.ម១៩៥+៦០០ នៅភូមិត្រពាំងធំ ភូមិអង្គរជា និងភូមិចាន់ទួល ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

**យោង** : -លិខិតលេខ១១២១៦១ សហវ.អថ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-កំណត់ហេតុចរចាថ្លៃថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ គ.ល ក្រសួងសាធារណការ និងដឹកជញ្ជូន
-លិខិតលេខ២៣០០ សក.អល ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមទេសរដ្ឋមន្ត្រីជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមតាមសំណើរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ប្រគល់កិច្ចសន្យាជូននាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ ដើម្បីធ្វើការងារស្ថាបនាផ្លូវខេត្តដោយចាក់ដីសពង្រីក និងលើកកម្ពស់តួថ្នល់សងខាងរួចក្រាលក្រួសក្រហម ប្រវែង ៣ ៧០០ម ទទឹង ៨ម ស្ថាបនាលូបេតុងមុខកាត់ ១ម សរុបចំនួន ០៣កន្លែង(១ជួរ ចំនួន ០២កន្លែង និង២ជួរ ចំនួន ០១កន្លែង) ដាំបង្គោលនាំផ្លូវ ចំនួន១២ដើម និងដាក់ស្លាកព័ត៌មានគម្រោង ចំនួន ០២ស្លាក ស្ថិតលើកំណាត់ផ្លូវខេត្តលេខ៧១C បំបែកពីផ្លូវជាតិលេខ៧ ត្រង់គ.ម១៩៥+៦០០ នៅភូមិត្រពាំងធំ ភូមិអង្គរជា និងភូមិចាន់ទួល ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ក្នុងតម្លៃសរុបចំនួន ៨៩៩.០០០.០០០រៀល (ប្រាំបីរយកៅសិបប្រាំបួនលានរៀលគត់) ជាតម្លៃកិច្ចសន្យា។

ការជួលបន្តទៅឱ្យក្រុមហ៊ុនឯកជនត្រូវបានហាមឃាត់ដាច់ខាត។ បើអង្គភាពរដ្ឋណាមួយគ្មានលទ្ធភាពធ្វើខ្លួនឯងបាន ត្រូវដកហូតប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តវិញ។ ក្នុងករណីប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្ត ត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមទេសរដ្ឋមន្ត្រីជ្រាប និងមានវិធានការអនុវត្តបន្តឱ្យសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ។

សូមឯកឧត្តមទេសរដ្ឋមន្ត្រី ទទួលនូវគារវកិច្ចពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**រដ្ឋលេខាធិការ**

**ជូ-វិជិត្ត**

**ចម្លងជូន**
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានថវិកា
- សាលាខេត្តត្បូងឃ្មុំ
- នាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ
- នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសាធារណៈ
- មន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តត្បូងឃ្មុំ
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តត្បូងឃ្មុំ
- ឯកសារ-កាលប្បវត្តិ